កំណែថ្មី 2406

# ការប្រឡងវាស់ជំនាញសម្រាប់ពលករជំនាញកម្រិត1 ក្នុងវិស័យផលិតអាហារនិងភេសជ្ជៈ

## សេចក្តីណែនាំអំពីការប្រឡងនៅក្នុងប្រទេសជប៉ុន

ស្ថាប័នវាយតម្លៃជំនាញបច្ចេកទេសឧស្សាហកម្មអាហារសម្រាប់ជនបរទេស

OTAFF

THE ORGANIZATION FOR TECHNICAL SKILL ASSESSMENT OF FOREIGN WORKERS IN FOOD INDUSTRY

<មាតិកា>


1. ពលករជំនាញ និង គោលដៅនៃការប្រឡង ........................................3

2. លក្ខខណ្ឌចូលរួមការប្រឡង ........................................4

3. មុខវិជ្ជាប្រឡង និង របៀបប្រឡង ជាដើម........................................5

4. ពិន្ទុជាប់........................................7

5. សៀវភៅសិក្សា ........................................7

6. ដំណើរការនៃនីតិវិធីប្រឡង និង ការហាមឃាត់ចំពោះការដាក់ពាក្យស្ទួន ................8

7. ថ្លៃប្រឡង........................................10

8. វត្ថុយកតាមខ្លួននៅថ្ងៃប្រឡង........................................10

9. ចំណុចប្រុងប្រយ័ត្ននៅថ្ងៃប្រឡង និង ការហាមឃាត់ទង្វើខុសវិន័យប្រឡង............16

10. ការប្រកាសបេក្ខជនប្រឡងជាប់ និង លិខិតបញ្ជាក់ការប្រឡងជាប់ ........................19

11. ការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន........................................21

## 1. ពលករជំនាញ និង គោលដៅនៃការប្រឡង

យោងតាមច្បាប់ក្រោយវិសោធនកម្មស្តីពីការគ្រប់គ្រងអន្តោប្រវេសន៍និងការទទួលស្គាល់ជនភៀសខ្លួនដែលបានចាប់ផ្តើមនៅថ្ងៃទី1 ខែមេសា ឆ្នាំ2019 លក្ខណៈសម្បត្តិស្នាក់នៅថ្មីហៅថា"ពលករជំនាញ"ត្រូវបានបង្កើតឡើង។

"ពលករជំនាញ" ជាប្រព័ន្ធដែលទទួលយកអ្នកដែលមានជំនាញបច្ចេកទេសពីក្រៅប្រទេសសម្រាប់ធ្វើការងារដែលកំពុងខ្វះកម្លាំងពលកម្មនៅប្រទេសជប៉ុន ដូចជា វិស័យផលិតអាហារនិងភេសជ្ជៈជាដើម។

ដើម្បីទទួលបានលក្ខណៈសម្បត្តិស្នាក់នៅជាពលករជំនាញកម្រិត1 នៅក្នុងវិស័យផលិតអាហារនិងភេសជ្ជៈ គឺត្រូវប្រឡងជាប់នៅក្នុងការប្រឡង "កម្រិតសមត្ថភាពជំនាញ"និង"កម្រិតសមត្ថភាពភាសាជប៉ុន"ទាំង2ផ្នែក។

"កម្រិតជំនាញភាសាជប៉ុន" នឹងត្រូវបានកំណត់ដោយ "ការប្រឡងមូលដ្ឋានគ្រឹះភាសាជប៉ុន(JFT-Basic)"ដែលអនុវត្តដោយមូលនិធិជប៉ុន ឬ "ការប្រឡងសមត្ថភាពជំនាញភាសាជប៉ុន(JLPT)"ដែលអនុវត្តដោយមូលនិធិជប៉ុននិងសមាគមគាំទ្រការអប់រំអន្តរជាតិជប៉ុន។

"កម្រិតសមត្ថភាពជំនាញ"នៅក្នុងវិស័យផលិតអាហារនិងភេសជ្ជៈ នឹងត្រូវបានកំណត់ដោយ"ការប្រឡងវាស់ជំនាញសម្រាប់ពលករជំនាញកម្រិត1ក្នុងវិស័យផលិតអាហារនិងភេសជ្ជៈ" ដែលអនុវត្តដោយស្ថាប័នវាយតម្លៃជំនាញបច្ចេកទេសឧស្សាហកម្មអាហារសម្រាប់ជនបរទេស (ខាងក្រោមហៅថា OTAFF)។ (OTAFF អាចនឹងប្រើពាក្យកាត់សម្រាប់ហៅឈ្មោះនៃការប្រឡងទៅតាមការចាំបាច់។)

ទាក់ទងនឹងការស្នើសុំការទទួលស្គាល់លើលក្ខណៈសម្បត្តិស្នាក់នៅជាពលករជំនាញ សូមទាក់ទងសាកសួរទៅភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុននៃក្រសួងយុត្តិធម៌។ OTAFF មិនអាចឆ្លើយតបក្រៅពីសំណួរដែលទាក់ទងនឹងការប្រឡងវាស់ជំនាញសម្រាប់ពលករជំនាញកម្រិត1 ក្នុងវិស័យភោជនីយដ្ឋាននិងវិស័យផលិតអាហារនិងភេសជ្ជៈបានទេ។

**[ការស្នើសុំលក្ខណៈសម្បត្តិស្នាក់នៅ "ពលករជំនាញកម្រិត1 (វិស័យផលិតអាហារនិងភេសជ្ជៈ)"]**

| កម្រិតសមត្ថភាពជំនាញ | កម្រិតសមត្ថភាពភាសាជប៉ុន |
|---|---|
| **ការប្រឡងពលករជំនាញកម្រិត1 ក្នុងវិស័យផលិតអាហារនិងភេសជ្ជៈ** | **ការប្រឡងមូលដ្ឋានគ្រឹះភាសាជប៉ុន (JFT-Basic) ឬ ការប្រឡងសមត្ថភាពជំនាញភាសាជប៉ុន (JLPT)** |
| 65%ឡើងទៅធៀបនឹងពិន្ទុពេញ | កម្រិតA2ឡើងទៅ (JFT-Basic) ឬក៏ កម្រិតN4ឡើងទៅ (JLPT) |

**ជាប់នៅក្នុងការប្រឡងទាំងពីរ**

↓

**ស្នើសុំទៅកាន់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន**

**※ ទោះជាបានប្រឡងជាប់ក៏ដោយ នោះមិនមែនមានន័យថាអ្នកប្រាកដជាទទួលបានលក្ខណៈសម្បត្តិស្នាក់នៅជា "ពលករជំនាញ" នោះទេ។**

**2. លក្ខខណ្ឌចូលរួមការប្រឡង**

អ្នកដែលអាចចូលរួមការប្រឡងពលករជំនាញក្នុងវិស័យផលិតអាហារនិងភេសជ្ជៈនៅក្នុងប្រទេសជប៉ុន ត្រូវមានលក្ខខណ្ឌ ក និង ខ ទាំងពីរព្រមគ្នានៅថ្ងៃប្រឡង។

ក. អ្នកដែលលក្ខណៈសម្បត្តិស្នាក់នៅ (ចំណាំ1) និង មានអាយុចាប់ពី17ឆ្នាំពេញឡើងទៅគិតត្រឹមថ្ងៃប្រឡង។

ខ. កាន់លិខិតឆ្លងដែន(ចំណាំ2)ដែលចេញដោយរដ្ឋាភិបាលក្រៅប្រទេសឬស្ថាប័នមានសមត្ថកិច្ចក្នុងតំបន់ដែលប្រកាសកំណត់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សម្រាប់ជាកិច្ចសហការនៅក្នុងការអនុវត្តដីកានិរទេសដោយរលូន។

(ចំណាំ1) អ្នកដែលកំពុងស្នាក់នៅក្នុងប្រទេសជប៉ុនដោយគោរពទៅតាមច្បាប់នៃប្រទេសជប៉ុនគឺអាចចូលរួមការប្រឡងបាន។ អ្នកដែលស្នាក់នៅប្រទេសជប៉ុនរយៈពេលខ្លីដោយគោរពទៅតាមច្បាប់នៃប្រទេសជប៉ុន ទោះជាគ្មានប័ណ្ណស្នាក់នៅក៏ដោយ ក៏អាចចូលរួមប្រឡងផងដែរ។ អ្នកដែលស្ថិតនៅក្នុងប្រទេសជប៉ុនដោយមិនគោរពទៅតាមច្បាប់នៃប្រទេសជប៉ុន (អ្នកស្នាក់នៅខុសច្បាប់) គឺមិនអាចចូលរួមការប្រឡងបានទេ។

(ចំណាំ2) បច្ចុប្បន្ន អ្នកដែលកាន់លិខិតឆ្លងដែននៃរដ្ឋាភិបាលក្រៅប្រទេសឬតំបន់ ក្រៅពីសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ គឺអាចចូលរួមការប្រឡងបាន។

(ចំណុចត្រូវប្រុងប្រយ័ត្ន)

- ■ ទោះជាបានជាប់នៅក្នុងការប្រឡងនេះក៏ដោយ ក៏មិនមែនមានន័យថាអ្នកប្រាកដជាទទួលបានលក្ខណៈសម្បត្តិស្នាក់នៅជា"ពលករជំនាញ"នោះដែរ។
  ទោះជាបានជាប់នៅក្នុងការប្រឡង ហើយបានដាក់ពាក្យស្នើសុំការប្រគល់លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ ឬ ការផ្លាស់ប្តូរលក្ខណៈសម្បត្តិស្នាក់នៅក៏ដោយ ក៏មិនមែនមានន័យថាអ្នកប្រាកដជាទទួលបានលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅនោះដែរ។

- ■ ទោះជាទទួលបានលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅក៏ដោយ ទាក់ទងនឹងទិដ្ឋាការ(វីសា) គឺត្រូវឆ្លងកាត់ការត្រួតពិនិត្យដាច់ដោយឡែកដោយក្រសួងយុត្តិធម៌ ដូច្នេះ មិនមែនមានន័យថាអ្នកប្រាកដជាទទួលបានទិដ្ឋាការ(វីសា)នោះឡើយ។

**3. មុខវិជ្ជាប្រឡង និង របៀបប្រឡង ជាដើម** (សំណួរប្រឡងទាំងអស់ត្រូវបានសរសេរជាភាសាជប៉ុន (សម្រាប់តួអក្សរកាន់ជិគីមានភ្ជាប់សម្លេងអាន)។)

**មុខវិជ្ជាប្រឡង : 2 មុខវិជ្ជា គឺ ការប្រឡងទ្រឹស្តី និង ការប្រឡងអនុវត្ត រយៈពេលប្រឡង : 70 នាទី**

**របៀបប្រឡង : ទម្រង់ប្រឡងដោយប្រើក្រដាស (ប្រើប្រាស់ក្រដាសគូសចម្លើយ។)**

**(1) ការប្រឡងទ្រឹស្តី**

នេះគឺជាការប្រឡងទៅលើចំណេះដឹងទាក់ទងនឹងការគ្រប់គ្រងអនាម័យទូទៅ និង អនាម័យសុវត្ថិភាពការងារតាមរយៈHACCPជាដើម។

| ចំណុច | ខ្លឹមសារសំខាន់ៗ | ចំនួនសំណួរ (សំណួរ) | ការដាក់ពិន្ទុ (ពិន្ទុ) | ពិន្ទុពេញ (ពិន្ទុ) |
|---|---|---|---|---|
| ចំណេះដឹងមូលដ្ឋានអំពីសុវត្ថិភាពចំណីអាហារនិងការគ្រប់គ្រងគុណភាព | · ភាពចាំបាច់នៃសុវត្ថិភាពចំណីអាហារ<br>· ចំណេះដឹងទាក់ទងនឹងការពុលអាហារ | 25 | 3 | 75 |
| មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងអនាម័យទូទៅ | · ចំណុចត្រូវយកចិត្តទុកដាក់ទាក់ទងនឹងការគ្រប់គ្រងអនាម័យនិងសុវត្ថិភាពចំណីអាហារ នៅមុនចាប់ផ្តើមធ្វើការងារ អំឡុងពេលធ្វើការងារ និង ក្រោយបញ្ចប់ការងារ។<br>· វិធានការនៃសកម្មភាព 5S<br>· ការគ្រប់គ្រងការជ្រៀតចូលនៃសារធាតុចម្លែក | | | |
| មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងដំណើរការផលិត | · ការគ្រប់គ្រងវត្ថុធាតុដើម<br>· ការគ្រប់គ្រងដំណើរការផលិត និង ចំណុចប្រុងប្រយ័ត្ន<br>· ការគ្រប់គ្រងផលិតផល<br>· ការគ្រប់គ្រងសារធាតុបង្ករោគប្រតិកម្ម | | | |
| ការគ្រប់គ្រងអនាម័យតាមរយៈ HACCP | · តើដូចម្តេចដែលហៅថា HACCP ?<br>· ការវិភាគកត្តាគ្រោះថ្នាក់<br>· គោលការណ៍ទាំង 7 នៃ HACCP<br>· មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងអនាម័យដោយHACCP | | | |
| ចំណេះដឹងទាក់ទងនឹងអនាម័យ និង សុវត្ថិភាពការងារ | · វិធានទប់ស្កាត់គ្រោះថ្នាក់នៅកន្លែងការងារ<br>· លំដាប់លំដោយការងារ និង ការអនុវត្ត 5S<br>· ការឆ្លើយតបនៅពេលកើតមានស្ថានភាពខុសប្រក្រតីជាដើម | 5 | 5 | 25 |
| សរុប | | 30 | | 100 |

(2) **ការប្រឡងអនុវត្ត** (មាន 2 គឺ "ការប្រឡងវិនិច្ឆ័យ" និង "ការរៀបចំផែនការ"។)

"ការប្រឡងវិនិច្ឆ័យ" គឺសំដៅទៅលើការប្រឡងធ្វើតេស្តថាតើអ្នកអាចធ្វើសកម្មភាពត្រឹមត្រូវដោយមើលរូបភាពឬគំនូរជាដើមបានដែរឬទេ ចំណែកឯ"ការរៀបចំផែនការ" គឺសំដៅទៅលើការប្រឡងធ្វើតេស្តថាតើអ្នកអាចបង្កើតផែនការការងារដោយប្រើរូបមន្តគណនាបានដែរឬទេ។

| ចំណុច | ខ្លឹមសារសំខាន់ៗ | ចំនួនសំណួរ (សំណួរ) | | | ការដាក់ពិន្ទុ (ពិន្ទុ) | ពិន្ទុពេញ (ពិន្ទុ) |
|---|---|---|---|---|---|---|
| | | ការប្រឡងវិនិច្ឆ័យ | ការរៀបចំផែនការ | សរុប | | |
| ចំណេះដឹងមូលដ្ឋានអំពីសុវត្ថិភាពចំណីអាហារ និង ការគ្រប់គ្រងគុណភាព | • ភាពចាំបាច់នៃសុវត្ថិភាពចំណីអាហារ<br>• ចំណេះដឹងទាក់ទងនឹងការពុលអាហារ | 4 | 2 | 6 | 5 | 30 |
| មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងអនាម័យទូទៅ | • ចំណុចត្រូវយកចិត្តទុកដាក់ទាក់ទងនឹងអនាម័យនិងសុវត្ថិភាព នៅមុនចាប់ផ្តើមធ្វើការងារ អំឡុងពេលធ្វើការងារ និង ក្រោយបញ្ចប់ការងារ។<br>• វិធានការនៃសកម្មភាព 5S<br>• ការគ្រប់គ្រងការជ្រៀតចូលនៃសារធាតុចម្លែក | | | | | |
| មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងដំណើរការផលិត | • ការគ្រប់គ្រងវត្ថុធាតុដើម<br>• ការគ្រប់គ្រងដំណើរការផលិត និង ចំណុចប្រុងប្រយ័ត្ន<br>• ការគ្រប់គ្រងផលិតផល<br>• ការគ្រប់គ្រងសារធាតុបង្ករោគប្រតិកម្ម | | | | | |
| ការគ្រប់គ្រងអនាម័យដោយ HACCP | • តើដូចម្តេចដែលហៅថា HACCP ?<br>• ការវិភាគកត្តាគ្រោះថ្នាក់<br>• គោលការណ៍ទាំង 7 នៃ HACCP<br>• មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងអនាម័យដោយ HACCP | | | | | |
| ចំណេះដឹងទាក់ទងនឹងអនាម័យនិងសុវត្ថិភាពការងារ | • វិធានទប់ស្កាត់គ្រោះថ្នាក់នៅកន្លែងការងារ<br>• លំដាប់លំដោយការងារ និង ការអនុវត្ត 5S<br>• ការឆ្លើយតបនៅពេលកើតមានស្ថានភាពខុសប្រក្រតីជាដើម | 4 | 0 | 4 | 5 | 20 |
| សរុប | | 8 | 2 | 10 | | 50 |

## 4. ពិន្ទុជាប់

ពិន្ទុជាប់ គឺ 65%ឡើងទៅធៀបនឹងពិន្ទុពេញ។

## 5. សៀវភៅសិក្សា

អ្នកអាចមើលសៀវភៅសិក្សាសម្រាប់បេក្ខជនប្រឡងនៅលើគេហទំព័រនៃស្ថាប័នវាយតម្លៃជំនាញបច្ចេកទេសឧស្សាហកម្មអាហារសម្រាប់ជនបរទេស (https://otaff1.jp/insyoku/)។

・ភាសាជប៉ុន៖ https://otaff1.jp/img/file/i_gakusyutext_jp.pdf

・ភាសាអង់គ្លេស៖ https://otaff1.jp/img/file/i_gakusyutext_en.pdf

・ភាសាវៀតណាម៖ https://otaff1.jp/img/file/i_gakusyutext_vn.pdf

・ភាសាឥណ្ឌូនេស៊ី៖ https://otaff1.jp/img/file/i_gakusyutext_in.pdf

・ភាសាមីយ៉ាន់ម៉ា៖ https://otaff1.jp/img/file/i_gakusyutext_my.pdf

・ភាសាចិន (អក្សរកាត់)៖ https://otaff1.jp/img/file/i_gakusyutext_cn.pdf

・ភាសាខ្មែរ៖ https://otaff1.jp/img/file/i_gakusyutext_kh.pdf

## 6. ដំណើរការនៃនីតិវិធីប្រឡង និង ការហាមឃាត់ចំពោះការដាក់ពាក្យស្ទួន

ជំហានទី1. អានខ្លឹមសារណែនាំអំពីការប្រឡង

សូមអានអំពីលក្ខខណ្ឌចូលរួមការប្រឡង មុខវិជ្ជាប្រឡងជាដើមដោយប្រុងប្រយ័ត្ន។

ជំហានទី2. ចុះឈ្មោះទំព័រខ្ញុំ

ការណែនាំអំពីការចុះឈ្មោះទំព័រខ្ញុំ

វិន័យទាក់ទងនឹងរូបថតសម្រាប់ការចុះឈ្មោះ

សូមអាន"ការណែនាំអំពីការចុះឈ្មោះទំព័រខ្ញុំ"ដោយប្រុងប្រយ័ត្ន រួចសូមចុះឈ្មោះដោយបញ្ចូលព័ត៌មាននិងរូបថតផ្ទៃមុខរបស់អ្នក។

ការចុះឈ្មោះទំព័រខ្ញុំនឹងត្រូវឆ្លងកាត់ការត្រួតពិនិត្យ ដែលត្រូវការរយៈពេលប្រមាណ5ថ្ងៃ (លើកលែងថ្ងៃសៅរ៍ ថ្ងៃអាទិត្យនិងថ្ងៃបុណ្យជាតិ)។

សូមចុះឈ្មោះឱ្យបានមុនថ្ងៃផុតកំណត់នៃការចុះឈ្មោះថ្មីសម្រាប់ទំព័រខ្ញុំ នៅមុនពេលដាក់ពាក្យចូលរួមការប្រឡង។

ករណីចុះឈ្មោះហួសថ្ងៃផុតកំណត់សម្រាប់ការចុះឈ្មោះថ្មី (ថ្ងៃផុតកំណត់ត្រូវបានកំណត់នៅរៀងរាល់ដងនៃការប្រឡង) ការត្រួតពិនិត្យនឹងត្រូវការរយៈពេលចាប់ពី1ខែឡើងទៅ។

រូបថតផ្ទៃមុខនឹងត្រូវបានប្រើប្រាស់សម្រាប់ការបញ្ជាក់សាមីខ្លួននៅតុទទួលភ្ញៀវនិងប្រើនៅលើលិខិតបញ្ជាក់ការប្រឡងជាប់។ សូមអាន"វិន័យទាក់ទងនឹងរូបថតសម្រាប់ការចុះឈ្មោះ"ដោយប្រុងប្រយ័ត្ន ដើម្បីចុះឈ្មោះបានត្រឹមត្រូវ។

[ការហាមឃាត់ចំពោះ "ការចុះឈ្មោះស្ទួន"] (ស្ទួន = ចាប់ពី 2 ឡើងទៅ)

**ការចុះឈ្មោះស្ទួនសម្រាប់ទំព័រខ្ញុំ**

មនុស្សម្នាក់អាចបង្កើតទំព័រខ្ញុំបានតែ 1 ប៉ុណ្ណោះ។

មនុស្សម្នាក់ដូចគ្នាមិនអាចបង្កើតទំព័រខ្ញុំចំនួន2បានទេ។

ជំហានទី3. ដាក់ពាក្យប្រឡង

ការណែនាំអំពីការដាក់ពាក្យប្រឡង

ទាក់ទងនឹងរបៀបដាក់ពាក្យ សូមអាន"ការណែនាំអំពីការដាក់ពាក្យប្រឡង"ដោយប្រុងប្រយ័ត្នមុននឹងដាក់ពាក្យ។

សូមចូលទៅកាន់ទំព័រខ្ញុំ រួចជ្រើសរើសកាលបរិច្ឆេទប្រឡង មណ្ឌលប្រឡងជាដើម ហើយសូមអានអំពីលក្ខខណ្ឌចូលរួមការប្រឡងម្តងទៀតមុននឹងដាក់ពាក្យ។ ក្រោយបញ្ចប់រយៈពេលនៃការដាក់ពាក្យប្រឡង អ្នកនឹងមិនអាចផ្លាស់ប្តូរកាលបរិច្ឆេទប្រឡងនិងមណ្ឌលប្រឡងបានទេ។

ប្រសិនបើការប្រកាសទទួលពាក្យប្រឡងលើកទី1មានចំនួនអ្នកដាក់ពាក្យតិចជាងចំនួនកំណត់ នោះនឹងមានការប្រកាសទទួលពាក្យប្រឡងលើកទី2។

[ការហាមឃាត់ចំពោះ "ការដាក់ពាក្យស្ទួន"] (ស្ទួន = ចាប់ពី 2 ឡើងទៅ)

**ការដាក់ពាក្យស្ទួនសម្រាប់ការប្រឡង**

ការដាក់ពាក្យប្រឡងក្នុងវិស័យភោជនីយដ្ឋាននិងវិស័យផលិតអាហារនិងភេសជ្ជៈ គឺចំនួន1ដងសម្រាប់ការប្រឡងនីមួយៗ ហើយកំណត់ត្រឹម 1 ដងប៉ុណ្ណោះសម្រាប់មនុស្សម្នាក់។

មនុស្សម្នាក់មិនអាចដាក់ពាក្យស្ទួនសម្រាប់ការប្រឡងនៅក្នុងវិស័យមួយដូចគ្នាបានទេ។

(ចំណាំ) បើអ្នកបង្កើតទំព័រផ្ទាល់ខ្លួនដែលស្ទួនគ្នា ហើយដាក់ពាក្យប្រឡងស្ទួនគ្នា អ្នកអាចនឹងមិនអាចចូលរួមការប្រឡងពលករជំនាញដែលអនុវត្តដោយOTAFFរយៈពេល 5 ឆ្នាំជាអតិបរមា។

ជំហានទី4. បើអ្នកត្រូវបានជ្រើសរើស សូមធ្វើការបង់ថ្លៃប្រឡង

※ការជ្រើសរើស គឺសំដៅទៅលើការចាប់ឆ្នោតដែលផ្តល់លទ្ធផលជាការត្រូវឬមិនត្រូវបានជ្រើសរើស។

ករណីចំនួនអ្នកដាក់ពាក្យលើសចំនួនកំណត់ នោះនឹងមានការជ្រើសរើសដោយ"ការចាប់ឆ្នោត※"។

លទ្ធផលពីការចាប់ឆ្នោតនឹងត្រូវបានជូនដំណឹងទៅកាន់អាសយដ្ឋានអ៊ីមែលដែលអ្នកបានចុះឈ្មោះ។

ម្យ៉ាងទៀត អ្នកក៏អាចមើលលទ្ធផលពីការចាប់ឆ្នោតនៅលើទំព័រខ្ញុំរបស់អ្នក ត្រង់ចំណុច"ប្រវត្តិនៃការប្រឡង"។

ចំពោះអ្នកដែលត្រូវបានជ្រើសរើស សូមបង់ថ្លៃប្រឡង(ប្រាក់)ឱ្យបានមុនថ្ងៃកំណត់។

សូមជ្រើសរើសវិធីបង់ប្រាក់មួយក្នុងចំណោមវិធីទាំង3 គឺ ការបង់តាមប័ណ្ណឥណទាន ការបង់តាមហាងទំនិញ24ម៉ោង និង ការបង់តាមPay-easy ។ ការបង់តាមហាងទំនិញ24ម៉ោង និង ការបង់តាមPay-easy គឺមិនអាចបង់ពីក្រៅប្រទេសជប៉ុនបានទេ។ អ្នកអាចបង់ប្រាក់តាមនោះនៅក្នុងប្រទេសជប៉ុន។

ថ្លៃប្រឡង(ប្រាក់)ដែលបានបង់រួច នឹងមិនអាចសងត្រឡប់ជូនវិញបានទេ។ (ចំណាំ)

ម្យ៉ាងទៀត អ្នកក៏មិនអាចផ្លាស់ប្តូរកាលបរិច្ឆេទនិងមណ្ឌលប្រឡងបានដែរ។

សូមពិនិត្យមើលកាលបរិច្ឆេទនិងមណ្ឌលប្រឡងម្តងទៀត មុននឹងធ្វើការបង់ប្រាក់។

(ចំណាំ) ករណីត្រូវបញ្ឈប់ការប្រឡងដោយសារគ្រោះធម្មជាតិជាដើម ថ្លៃប្រឡង(ប្រាក់)នឹងត្រូវបានសងត្រឡប់ជូនវិញ។

សម្រាប់ខ្លឹមសារលម្អិត សូមមើល "7. ថ្លៃប្រឡង"។

ជំហានទី5. ទាញយកប័ណ្ណប្រឡង

អ្នកអាចទាញយកប័ណ្ណប្រឡងបានពី "ប្រវត្តិនៃការប្រឡង" នៅលើទំព័រខ្ញុំ។

សម្រាប់ថ្ងៃចាប់ផ្តើមទាញយក សូមមើលចំណុច"ការផ្តល់ប័ណ្ណប្រឡង" នៅក្នុង"កាលវិភាគប្រឡង(ដំណើរការទាំងមូល)" នៅលើគេហទំព័រនៃ OTAFF ។

ម្យ៉ាងទៀត ក៏មានការជូនដំណឹងអំពីការអាចទាញយកប័ណ្ណប្រឡងតាមរយៈអ៊ីមែលដែលអ្នកបានចុះឈ្មោះផងដែរ។

ជំហានទី6. ចូលរួមការប្រឡង

មុននឹងចូលរួមការប្រឡង សូមអាន "9. ចំណុចប្រុងប្រយ័ត្ននៅថ្ងៃប្រឡង និង ការហាមឃាត់ទង្វើខុសវិន័យប្រឡង" ឱ្យបានយល់ច្បាស់។

នៅថ្ងៃប្រឡង សូមយកតាមខ្លួននូវ "ប័ណ្ណប្រឡង" "ប័ណ្ណស្នាក់នៅ" "លិខិតឆ្លងដែន" "ខ្មៅដៃHB" "ជ័រលុប" និង "ម៉ាស៊ីនគិតលេខ(សម្រាប់អ្នកដែលចង់ប្រើប៉ុណ្ណោះ)"។

សម្រាប់ខ្លឹមសារលម្អិត សូមអាន "8. វត្ថុយកតាមខ្លួននៅថ្ងៃប្រឡង" ដោយប្រុងប្រយ័ត្ន។

នៅមណ្ឌលប្រឡង សូមចូលរួមការប្រឡង ក្រោយឆ្លងកាត់ការពិនិត្យបញ្ជាក់សាមីខ្លួននៅតុទទួលភ្ញៀវ។

ជំហានទី7. លទ្ធផលប្រឡងជាប់ឬធ្លាក់

អ្នកអាចមើលលទ្ធផលប្រឡងជាប់ឬធ្លាក់នៅលើគេហទំព័រនៃ OTAFF និងត្រង់"ប្រវត្តិនៃការប្រឡង"នៃទំព័រខ្ញុំ ក្នុងអំឡុងពេលប្រមាណ3សប្តាហ៍ក្រោយបញ្ចប់កាលវិភាគនៃការប្រឡងទាំងអស់។ ទោះតាមនីតិវិធី ការប្រកាសលទ្ធផលប្រឡងគឺអាចយឺតយ៉ាវបន្ថែមទៀត។

សម្រាប់ព័ត៌មានលម្អិត សូមពិនិត្យមើល "កាលវិភាគប្រចាំឆ្នាំ" (https://otaff1.jp/schedule/schedule_jp.pdf)។ យើងខ្ញុំក៏ជូនដំណឹងអំពីការប្រកាសលទ្ធផលជាសាធារណៈតាមរយៈអ៊ីមែលដែលអ្នកបានចុះឈ្មោះផងដែរ។

សូមបញ្ជាក់ថាយើងខ្ញុំមិនអាចឆ្លើយតបចំពោះការសាកសួរទាក់ទងនឹងលទ្ធផលប្រឡងបានទេ។

ជំហានទី8. ទទួលលិខិតបញ្ជាក់ការប្រឡងជាប់

សម្រាប់អ្នកដែលបានប្រឡងជាប់ គឺនឹងមានការផ្តល់លិខិតបញ្ជាក់ការប្រឡងជាប់នៅក្នុង"ប្រវត្តិនៃការប្រឡង"នៃទំព័រខ្ញុំ។ អ្នកអាចទាញយកលិខិតបញ្ជាក់ការប្រឡងជាប់បានដោយខ្លួនឯង ដូច្នេះ សូមបោះពុម្ពលិខិតនោះដោយខ្លួនឯងនៅពេលចាំបាច់។ OTAFF នឹងមិនអាចទាញយក ហើយបោះពុម្ពឬផ្ញើលិខិតនោះតាមប្រៃសណីយ៍បានទេ។

## 7. ថ្លៃប្រឡង

8,000 យេន (រួមទាំងពន្ធ)

ថ្លៃប្រឡង(ប្រាក់)ដែលបានបង់រួច នឹងមិនអាចសងត្រឡប់ជូនវិញបានទេ។

ប៉ុន្តែ ចំពោះករណីដូចខាងក្រោម នឹងមានការសងថ្លៃប្រឡង(ប្រាក់)ជូនវិញ។

・ករណីមិនអាចប្រឡងបាន ដោយសារបញ្ហាខាងOTAFF

・ករណី OTAFF សម្រេចថាមិនអាចប្រឡងបាន ដោយសារគ្រោះធម្មជាតិជាដើម។

(ករណីមានការប្រឡងជំនួស គឺនឹងមិនសងថ្លៃប្រឡង(ប្រាក់)វិញទេ)

សូមមើលគេហទំព័រ OTAFF ដោយប្រុងប្រយ័ត្ន ដើម្បីដឹងថាតើអ្នកអាចប្រឡងបានឬទេ។

## 8. វត្ថុយកតាមខ្លួននៅថ្ងៃប្រឡង

សូមអ្នកយកវត្ថុ①ដល់⑥ដូចខាងក្រោមមកតាមខ្លួន។

នៅពេលប្រឡង អ្នកអាចប្រើម៉ាស៊ីនគិតលេខ(កាល្ស៊ូ)បាន។ ចំពោះអ្នកដែលចង់ប្រើម៉ាស៊ីនគិតលេខ សូមយកមកដោយខ្លួនឯង។

នៅតុទទួលភ្ញៀវ នឹងមានការពិនិត្យបញ្ជាក់ឈ្មោះនិងថ្ងៃខែឆ្នាំកំណើតជាដើម។

ករណីមិនអាចពិនិត្យបញ្ជាក់បាន អ្នកមិនអាចចូលរួមការប្រឡងបានទេ។

① ប័ណ្ណប្រឡង

② ប័ណ្ណស្នាក់នៅ (សូមអានចំណុចចំណាំ1 និង ចំណាំ2 ឱ្យបានយល់ច្បាស់។)

③ លិខិតឆ្លងដែន (សូមអានចំណុចចំណាំ3 ឱ្យបានយល់ច្បាស់។)

④ ខ្មៅដៃHB (ចំណាំ4)

⑤ ជ័រលុប

⑥ ម៉ាស៊ីនគិតលេខ (ចំណុចប្រុងប្រយ័ត្នទាក់ទងនឹងម៉ាស៊ីនគិតលេខដែលអាចប្រើបាន៖ ចំណាំ5)

(ចំណាំ1) អ្នកដែលហួសថ្ងៃផុតកំណត់នៃប័ណ្ណស្នាក់នៅគិតត្រឹមថ្ងៃប្រឡង

នៅថ្ងៃប្រឡង សូមយកតាមខ្លួននូវវត្ថុមួយក្នុងចំណោម i) ដល់ iii) កុំខានឱ្យសោះ។

i) ប័ណ្ណស្នាក់នៅដែលមានត្រាដាក់ថា"កំពុងស្នើសុំ" នៅផ្នែកស្នើសុំការអនុញ្ញាតការពន្យាររយៈពេលស្នាក់នៅជាដើមនៅផ្ទៃខាងក្រោយ។

ii) ឯកសារបោះពុម្ពនៃអ៊ីមែលដែលបញ្ជាក់ថាបានទទួលពាក្យរួចរាល់សម្រាប់ការដាក់ពាក្យស្នើសុំការស្នាក់នៅតាមប្រព័ន្ធអនឡាញនៃភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន (**គំរូ1**) និង ឯកសារថតចម្លងមានពណ៌នៃប័ណ្ណស្នាក់នៅ (សងខាង មុខនិងក្រោយ)

iii) លិខិតបង្កាន់ដៃសម្រាប់នីតិវិធីពន្យារប័ណ្ណស្នាក់នៅ (**គំរូ2**)

※ គំរូ1គឺនៅទំព័រ13 ហើយគំរូ2គឺនៅទំព័រ14។

(ចំណាំ2) អ្នកដែលកំពុងដំណើរការនីតិវិធីពន្យារប័ណ្ណស្នាក់នៅ ហើយមិនអាចយកប័ណ្ណមកនៅថ្ងៃប្រឡង

នៅថ្ងៃប្រឡង សូមយកតាមខ្លួននូវវត្ថុមួយក្នុងចំណោម i) និង ii) កុំខានឱ្យសោះ។

i) ឯកសារបោះពុម្ពនៃអ៊ីមែលដែលបញ្ជាក់ថាបានទទួលពាក្យរួចរាល់សម្រាប់ការដាក់ពាក្យស្នើសុំការស្នាក់នៅតាមប្រព័ន្ធអនឡាញនៃភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន (**គំរូ1**) និង ឯកសារថតចម្លងមានពណ៌នៃប័ណ្ណស្នាក់នៅ (សងខាង មុខនិងក្រោយ)

ii) លិខិតបង្កាន់ដៃសម្រាប់នីតិវិធីពន្យារប័ណ្ណស្នាក់នៅ (**គំរូ2**)

※ គំរូ1គឺនៅទំព័រ13 ហើយគំរូ2គឺនៅទំព័រ14។

(ចំណាំ3) អ្នកដែលគ្មានប័ណ្ណស្នាក់នៅ ដោយយកតែលិខិតឆ្លងដែនមក

នៅថ្ងៃប្រឡង បុគ្គលិកនឹងពិនិត្យក្រដាសបិទដែលសរសេរអំពីរយៈពេលស្នាក់នៅនៅលើលិខិតឆ្លងដែន (**គំរូ3**) ឬ ទំព័រដែលមានត្រាកៅស៊ូបញ្ជាក់ថាបានទទួលពាក្យស្នើសុំរួចរាល់។ ករណីមិនអាចពិនិត្យបញ្ជាក់បាន អ្នកនឹងមិនអាចចូលរួមការប្រឡងបានទេ។

※ គំរូ3គឺនៅទំព័រ15។

[សំខាន់] ចំពោះអ្នកដែលកំពុងដាក់ពាក្យស្នើសុំជាជនភៀសខ្លួន សូមទាក់ទងទៅកាន់OTAFFទុកជាមុនកុំខានឱ្យសោះ។

អ្នកដែលមិនបានទាក់ទងទៅOTAFFទុកជាមុន ហើយនៅថ្ងៃប្រឡងគ្មានឯកសារដែលចាំបាច់សម្រាប់ការពិនិត្យលក្ខណៈសម្បត្តិស្នាក់នៅទេ នោះនឹងមិនអាចចូលរួមការប្រឡងបានទេ។

ទូរសព្ទ៖ 03-6261-4949 (ថ្ងៃច័ន្ទដល់សុក្រ ពីម៉ោង 9ដល់12 និង ពីម៉ោង13ដល់17)

អ៊ីមែល tokutei@otaff.or.jp (ចំណងជើងអ៊ីមែល៖ ខ្ញុំជាបេក្ខជនប្រឡងដែលកំពុងដាក់ពាក្យស្នើសុំជាជនភៀសខ្លួន)

នៅក្នុងអ៊ីមែល សូមភ្ជាប់រូបថតនៃលិខិតឆ្លងដែន និង រូបថតនៃឯកសារដែលបានទទួលពីការិយាល័យអន្តោប្រវេសន៍ដូចជាបង្កាន់ដៃទទួលពាក្យស្នើសុំការទទួលស្គាល់ជនភៀសខ្លួនជាដើម។

(ចំណាំ4) អ្នកមិនអាចប្រើខ្មៅដៃចុច ខ្មៅដៃកង់ និង ប្រដាប់ខួងខ្មៅដៃបានទេ។

**(ចំណាំ5)** អ្នកអាចប្រើម៉ាស៊ីនគិតលេខ(កាស្យូ)បាន ប៉ុន្តែ ខាងក្រោមគឺជាចំណុចប្រុងប្រយ័ត្នទាក់ទងនឹងម៉ាស៊ីនគិតលេខដែលអាចប្រើបាន។

① ត្រឹមមានមុខងារបូកដកគុណចែក(+-×÷)សម្រាប់ដោះស្រាយលំហាត់គណនាគឺគ្រប់គ្រាន់ហើយ។

② មុខងារចងចាំគឺកំណត់ត្រឹមអាចចងចាំលទ្ធផលគណនាតែ1ប៉ុណ្ណោះ។

③ មុខងារចងចាំដែលលើសពីមុខងារចងចាំនៅចំណុច②គឺមិនអាចប្រើប្រាស់បានទេ។ (អ្នកមិនអាចប្រើប្រាស់ម៉ាស៊ីនគិតលេខដែលមានមុខងារចងចាំអាចកត់ត្រាលទ្ធផលគណនាច្រើន ឬ អាចត្រឡប់មើលលទ្ធផលគណនាកន្លងមក ឬ អាចកត់ត្រាតួអក្សរជាដើមបានទេ។)

④ អ្នកមិនអាចប្រើម៉ាស៊ីនគិតលេខដែលមានមុខងារឆ្លងឆ្លើយទេ។ (អ្នកមិនអាចប្រើប្រាស់ទូរសព្ទទំនើបធ្វើជាម៉ាស៊ីនគិតលេខបានទេ។)

⑤ អ្នកមិនអាចប្រើប្រាស់ម៉ាស៊ីនគិតលេខដែលមានមុខងារបញ្ចូលកម្មវិធីបានទេ។

⑥ ករណីអ្នកប្រើប្រាស់ម៉ាស៊ីនគិតលេខដែលមានមុខងារក្រៅពីមុខងារដែលបានសរសេរនៅ①និង② អ្នកនឹងបាត់បង់សិទ្ធិប្រឡងនៅនឹងកន្លែង ហើយនឹងមិនត្រូវបានផ្តល់ពិន្ទុឡើយ។

⑦ ករណីអ្នកប្រើប្រាស់ម៉ាស៊ីនគិតលេខ(កាស្យូ)ដែលមានមុខងារខ្ពស់ជាងមុខងារបូកដកគុណចែក(+-×÷)ហើយត្រូវបានសង្ស័យថាបានប្រព្រឹត្តទង្វើខុសវិន័យប្រឡង មេប្រយោគនឹងបញ្ឈប់ការប្រើប្រាស់ ហើយអ្នកអាចនឹងបាត់បង់សិទ្ធិប្រឡង។

គំរូ1

【在留資格オンラインシステム】申請受付完了のお知らせ

〇〇様

(本メールは、在留資格オンラインシステムから自動的に送信しております)

申請受付日：XXXX 年 XX 月 XX 日

申請受付仮番号：XXXXXXXXXXX

在留種別：在留資格認定証明書交付申請　Certificate of eligibility

申請人在留カード等番号：XXXXXXXXXXX

の申請について、申請受付番号をお知らせいたします。

申請受付番号：XXXXXXXXXXX

本メールは、申請中であることを証明するものとなりますので、資料者及び申請人の方は申請中は本メールを削除しないように保存し、必要に応じて印刷するなどして携行してください。

Sample

**គំរូ2**

សូមអានចំណុច (ចំណាំ1និង2) នៃ "8. វត្ថុយកតាមខ្លួននៅថ្ងៃប្រឡង" នៅក្នុងសេចក្តីណែនាំអំពីការប្រឡងនៅក្នុងប្រទេសជប៉ុន ដោយប្រុងប្រយ័ត្ន រួចសូមឱ្យក្រុមហ៊ុន សមាគម សាលារៀនជាដើមរបស់អ្នកសរសេរលើលិខិត ហើយសូមយកលិខិតនោះមកតាមខ្លួននៅថ្ងៃប្រឡង។

## លិខិតបង្កាន់ដៃសម្រាប់នីតិវិធីពន្យារប័ណ្ណស្នាក់នៅ

យើងខ្ញុំបានរក្សាទុកប័ណ្ណស្នាក់នៅរបស់បុគ្គលខាងក្រោម សម្រាប់ការអនុវត្តនីតិវិធីពន្យាររយៈពេលស្នាក់នៅជាដើម។

កាលបរិច្ឆេទសរសេរ៖ ថ្ងៃទី ខែ ឆ្នាំ

① ឈ្មោះ (អក្សរក្រមអង់គ្លេស) ______

② លេខលិខិតឆ្លងដែន ______

③ ច្បាប់ចម្លងនៃប័ណ្ណស្នាក់នៅមុនពេលពន្យារ (សងខាង មុខនិងក្រោយ)

| | |
|---|---|
| បិទច្បាប់ចម្លងមានពណ៌នៃប័ណ្ណស្នាក់នៅ មុនពេលពន្យារ (ផ្ទៃខាងមុខ) | បិទច្បាប់ចម្លងមានពណ៌នៃប័ណ្ណស្នាក់នៅ មុនពេលពន្យារ (ផ្ទៃខាងក្រោយ) |

④ ឈ្មោះអង្គភាព អាសយដ្ឋាន ឈ្មោះអ្នកទទួលបន្ទុក មធ្យោបាយទំនាក់ទំនងអ្នកទទួលបន្ទុក និង ត្រា នៃអង្គភាពដែលកំពុងរក្សាទុកប័ណ្ណស្នាក់នៅសម្រាប់នីតិវិធីពន្យារការស្នាក់នៅ

**គំរូ3**




[សំខាន់]
រយៈពេលស្នាក់នៅគឺត្រូវតែជាកាលបរិច្ឆេទ
គិតចាប់ពីថ្ងៃប្រឡងទៅ។
<u>※អ្នកដែលហួសរយៈពេលស្នាក់នៅ ចាំបាច់ត្រូវមានត្រាដែលបញ្ជាក់ថាបានទទួលពាក្យស្នើសុំពន្យារ (មានសុពលភាពរយៈពេល2ខែ គិតចាប់ពីថ្ងៃស្នើសុំ)</u>

ការស្នាក់នៅរយៈពេលខ្លី និង
សកម្មភាពកំណត់ជាដើម
ក៏អាចបានដែរ

## 9. ចំណុចប្រុងប្រយ័ត្ននៅថ្ងៃប្រឡង និង ការហាមឃាត់ទង្វើខុសវិន័យប្រឡង

(1) ការប្រុងប្រយ័ត្ននៅមុនពេលមកមណ្ឌលប្រឡង

អ្នកដែលមានរោគសញ្ញាក្តៅខ្លួនឬមានអារម្មណ៍មិនស្រួលខ្លួនអាចនឹងមិនអាចចូលរួមការប្រឡងបានទេ។

(2) ការប្រុងប្រយ័ត្ននៅតុទទួលភ្ញៀវ

① សូមយក①ដល់⑥នៅក្នុង "8. វត្ថុយកតាមខ្លួននៅថ្ងៃប្រឡង" មក កុំខានឱ្យសោះ។

② នៅតុទទួលភ្ញៀវនឹងមានការពិនិត្យបញ្ជាក់សាមីខ្លួន។ នៅពេលពិនិត្យមុខ សូមដោះម៉ាស់ចេញ។

③ សូមដោះមួក វ៉ែនតាខ្មៅ កាសស្តាប់ និង កាសត្រចៀក ហើយដាក់វត្ថុទាំងនោះទៅក្នុងកាបូបឬថង់។

④ បើរូបថតដែលបានចុះឈ្មោះនៅទំព័រខ្ញុំមិនច្បាស់ល្អ សូមថតរូបសារជាថ្មីម្តងទៀត។
ចំពោះអ្នកដែលត្រូវបានប្រាប់ឱ្យ"ថតរូបសារជាថ្មី" សូមស្តាប់និងអនុវត្តតាមការណែនាំរបស់បុគ្គលិក។

⑤ អ្នកដែលរួចរាល់នៅតុទទួលភ្ញៀវ គឺអាចចូលទៅក្នុងបន្ទប់ប្រឡងបាន។

※សូមមកដល់តុទទួលភ្ញៀវយ៉ាងហោចណាស់15នាទីមុនការប្រឡងចាប់ផ្តើម។ បើអ្នកមិនបានមកដល់នៅ15នាទីមុនទេ អ្នកអាចនឹងមិនអាចចូលរួមការប្រឡងបានទេ។
ករណីមកដល់យឺតពេល ហួសម៉ោងចាប់ផ្តើមការប្រឡង អ្នកនឹងមិនអាចចូលរួមការប្រឡងបានទេ។

(ចំណាំ) នៅពេលអាកាសធាតុមិនល្អ រថភ្លើងនិងរថយន្តក្រុងអាចនឹងយឺតយ៉ាវ។
សូមអ្នកមកដល់មណ្ឌលប្រឡងឱ្យបានឆាប់រហ័ស។

(3) ការប្រុងប្រយ័ត្ននៅក្នុងបន្ទប់ប្រឡង

① សូមអ្នកអង្គុយនៅកៅអីដែលមានលេខដូចទៅនឹង"លេខកៅអី"ដែលបង្ហាញនៅលើ"ប័ណ្ណប្រឡង"។

② បើអ្នកចាកចេញឬចូលបន្ទប់ប្រឡង នៅមុនការប្រឡងចាប់ផ្តើម សូមយក"ប័ណ្ណប្រឡង"តាមខ្លួនជានិច្ច។

③ សូមអ្នកចូលក្នុងបន្ទប់ប្រឡងយ៉ាងហោចណាស់15នាទីមុនការប្រឡងចាប់ផ្តើម។

④ នៅក្នុងបន្ទប់ សូមកុំជជែកគ្នា។

⑤ នៅក្នុងបន្ទប់ សូមកុំបរិភោគអាហារឬផឹកភេសជ្ជៈ។

⑥ ក្រោយការប្រឡងបានចាប់ផ្តើម អ្នកនឹងមិនអាចចូលក្នុងបន្ទប់បានឡើយ។

- សូមដាក់ប័ណ្ណប្រឡងនៅក្បែរលេខកៅអីរបស់អ្នក។
- នៅលើតុ សូមដាក់ខ្មៅដៃHB ជ័រលុប និង ម៉ាស៊ីនគិតលេខ (សម្រាប់អ្នកដែលចង់ប្រើប៉ុណ្ណោះ)។
  សូមដាក់វត្ថុក្រៅពីនោះចូលទៅក្នុងកាបូបឬថង់ រួចបិទកាបូបនិងដាក់ក្រោមកៅអី។ អ្នកមិនអាចប្រើខ្មៅដៃចុច ខ្មៅដៃកង់ និង ប្រដាប់ខួងខ្មៅដៃជាដើមបានទេ។
- សម្រាប់ទូរសព្ទដៃ ទូរសព្ទទំនើបជាដើម សូមបិទនិងទទួលការពិនិត្យពីបុគ្គលិកកុំខានឱ្យសោះ រហូតដល់ពេលអ្នកចាកចេញពីបន្ទប់ប្រឡង។
  សូមប្រាកដថាអ្នកដឹងអំពីរបៀបបិទ ហើយអាចបិទដោយខ្លួនឯងបាន។
  ក្រោយពេលបុគ្គលិកពិនិត្យរួចរាល់ហើយ សូមដាក់ចូលទៅក្នុងកាបូបឬថង់ ហើយបិទកាបូប និងដាក់ក្រោមកៅអី។
- នាឡិកាគឺមាននៅក្នុងបន្ទប់ប្រឡង។ អ្នកមិនអាចប្រើនាឡិកាផ្ទាល់ខ្លួនបានទេ។
- សូមបិទសម្លេងរោទិ៍នៃនាឡិការបស់អ្នក រួចដាក់ចូលទៅក្នុងកាបូបឬថង់ ហើយបិទកាបូប និងដាក់ក្រោមកៅអី។
  ក្នុងពេលប្រឡង អ្នកមិនអាចដាក់នាឡិកានៅលើតុ ឬ ពាក់នាឡិកានៅលើដៃបានទេ។
  អ្នកមិនអាចប្រើទូរសព្ទដៃឬទូរសព្ទទំនើបជាដើមសម្រាប់ធ្វើជានាឡិកាបានទេ។
  ក្នុងពេលប្រឡង បើមានសម្លេងរោទិ៍ឬសម្លេងញ័រពីទូរសព្ទដៃ ទូរសព្ទទំនើបឬនាឡិកា អ្នកអាចនឹងមិនអាចចូលរួមការប្រឡងបានទេ។
  សូមប្រុងប្រយ័ត្នកុំឱ្យមានសម្លេងរោទិ៍ឡើងឱ្យសោះ។
- អ្នកអាចប្រើម៉ាស៊ីនគិតលេខ(កាស្យូ)បាន។ អ្នកដែលចង់ប្រើម៉ាស៊ីនគិតលេខ សូមយកមកដោយខ្លួនឯង។ សូមពិនិត្យមើល (ចំណាំ 5)

នៅក្នុង "8. វត្ថុយកតាមខ្លួននៅថ្ងៃប្រឡង។"

- នៅក្នុងបន្ទប់ប្រឡង សូមស្តាប់ដោយយកចិត្តទុកដាក់ និង អនុវត្តតាមការណែនាំរបស់បុគ្គលិក។
  បើអ្នកមិនស្តាប់ការណែនាំរបស់បុគ្គលិកទេ អ្នកអាចនឹងមិនអាចចូលរួមការប្រឡងបានទេ។

(4) ការប្រុងប្រយ័ត្ននៅមុនពេលការប្រឡងចាប់ផ្តើម

- សូមដាក់តែប័ណ្ណប្រឡង ខ្មៅដៃHB ជ័រលុប ម៉ាស៊ីនគិតលេខ(សម្រាប់អ្នកដែលចង់ប្រើប៉ុណ្ណោះ) ក្រដាសគូសចម្លើយនិង"ឧទាហរណ៍នៃការសរសេរលើក្រដាសគូសចម្លើយនិងចំណុចប្រុងប្រយ័ត្នសម្រាប់ការប្រឡង"ដែលបានចែកនៅក្នុងបន្ទប់ប្រឡងប៉ុណ្ណោះនៅលើតុ។
  សូមដាក់វត្ថុក្រៅពីនោះចូលទៅក្នុងកាបូបឬថង់ រួចបិទកាបូបនិងដាក់ក្រោមកៅអី។
- សូមពិនិត្យមើល"ឧទាហរណ៍នៃការសរសេរលើក្រដាសគូសចម្លើយ"ដោយប្រុងប្រយ័ត្ន ហើយសូមសរសេរឈ្មោះរបស់ខ្លួននៅលើក្រដាសគូសចម្លើយកុំឱ្យខុសឱ្យសោះ។
- សូមពិនិត្យមើលថាតើអត្តលេខប្រឡងដែលបោះពុម្ពនៅលើក្រដាសគូសចម្លើយ និង អត្តលេខប្រឡងដែលបានផាត់ពណ៌ខ្មៅ ត្រូវនឹងអត្តលេខប្រឡងរបស់ខ្លួនអ្នកដែរឬទេ។
- អ្នកដែលសរសេរអក្សរឬលេខនៅលើរាងកាយឬសម្លៀកបំពាក់ជាដើម នឹងត្រូវបានចាត់ទុកថាជាទង្វើបន្លំ ហើយអាចនឹងត្រូវបានសុំឱ្យចាកចេញពីបន្ទប់ប្រឡងនិងមិនអាចចូលរួមការប្រឡងបាន។ សូមអ្នកកុំសរសេរអក្សរឬលេខនៅលើរាងកាយឬសម្លៀកបំពាក់ជាដើម។
- សូមកុំពាក់មួកឬវ៉ែនតាខ្មៅនៅក្នុងបន្ទប់ប្រឡង។
  ម្យ៉ាងទៀត អ្នកមិនអាចប្រើកាសស្តាប់ឬកាសត្រចៀកបានទេ។
  សូមដាក់ចូលទៅក្នុងកាបូបឬថង់ រួចបិទកាបូបនិងដាក់ក្រោមកៅអី។
- ក្នុងពេលប្រឡង សូមប្រើតែខ្មៅដៃHB ជ័រលុប និង ម៉ាស៊ីនគិតលេខ(សម្រាប់អ្នកដែលចង់ប្រើ ប៉ុណ្ណោះ)។ ក្នុងពេលប្រឡង អ្នកមិនអាចប្រើខ្មៅដៃចុច ខ្មៅដៃកង់ និង ប្រដាប់ខួងខ្មៅដៃបានទេ។ សូមដាក់ចូលទៅក្នុងកាបូបឬថង់ រួចបិទកាបូបនិងដាក់ក្រោមកៅអី។
- សូមទៅបន្ទប់ទឹករួចរាល់យ៉ាងហោចណាស់15នាទីមុនពេលការប្រឡងចាប់ផ្តើម។
- មុនចាប់ផ្តើមការប្រឡងនឹងមានការចែកក្រដាសសំណួរ។
  សូមកុំបើកក្រដាសសំណួរឬសរសេរចម្លើយ រហូតដល់ពេលដែលបុគ្គលិកនិយាយថា"សូមចាប់ផ្តើម"។

(5) ការប្រុងប្រយ័ត្នបន្ទាប់ពីការប្រឡងបានចាប់ផ្តើម

- សូមសរសេរចម្លើយនៅលើក្រដាសគូសចម្លើយ។
  ទោះជាអ្នកសរសេរចម្លើយនៅលើក្រដាសសំណួរ ក៏នឹងមិនត្រូវបានផ្តល់ពិន្ទុដែរ។
- បើគូសចម្លើយខុស សូមប្រើជ័រលុបដើម្បីលុបឱ្យបានស្អាត។
  សូមកុំធ្វើឱ្យក្រដាសគូសចម្លើយប្រឡាក់ឬបត់។
  ម៉ាស៊ីនដែលអានក្រដាសគូសចម្លើយអាចនឹងមិនអាចអានបានត្រឹមត្រូវ។
  បើម៉ាស៊ីនមិនអាចអានត្រឹមត្រូវបានទេ អ្នកនឹងមិនត្រូវបានផ្តល់ពិន្ទុឡើយ។
- បើអ្នកទៅបន្ទប់ទឹកក្នុងអំឡុងពេលប្រឡង អ្នកនឹងមិនអាចចូលក្នុងបន្ទប់ប្រឡងម្តងទៀតបានទេ។
  សូមទៅបន្ទប់ទឹករួចរាល់យ៉ាងហោចណាស់15នាទីមុនពេលការប្រឡងចាប់ផ្តើម។
- ក្រោយចាប់ផ្តើមការប្រឡងបានកន្លងទៅ30នាទី បុគ្គលិកនឹងប្រកាសប្រាប់។
  ក្រោយពេលបុគ្គលិកពិនិត្យ រួចប្រាប់ថា"អាចចាកចេញបាន" អ្នកអាចចាកចេញពីបន្ទប់បាន។
  ក្រោយពេលចាកចេញពីបន្ទប់ អ្នកនឹងមិនអាចចូលក្នុងបន្ទប់ម្តងទៀតបានឡើយ។
  ពេលអ្នកចាកចេញពីបន្ទប់ម្តង ការប្រឡងរបស់អ្នកគឺចាត់ទុកថាបានបញ្ចប់។
- សូមកុំជជែកគ្នានៅក្បែរបន្ទប់ប្រឡង។
- អ្នកមិនអាចចាកចេញពីបន្ទប់ទេ រហូតដល់រយៈពេល10នាទីមុនការប្រឡងបញ្ចប់។
- យើងខ្ញុំមិនអាចឆ្លើយតបចំពោះសំណួរដែលទាក់ទងនឹងខ្លឹមសារនៃសំណួរបានទេ។
- បើអ្នកមិនស្រួលខ្លួនក្នុងអំឡុងពេលប្រឡង សូមលើកដៃដើម្បីប្រាប់ទៅដល់បុគ្គលិក។
- សូមស្តាប់ដោយយកចិត្តទុកដាក់និងអនុវត្តទៅតាមការណែនាំរបស់បុគ្គលិក។

(6) ការប្រុងប្រយ័ត្ននៅពេលចាកចេញពីបន្ទប់

- នៅពេលត្រូវចាកចេញពីបន្ទប់ក្នុងអំឡុងពេលប្រឡង សូមអ្នករក្សាការអង្គុយនៅកន្លែង ដោយលើកដៃជានិច្ចដើម្បីប្រាប់ទៅដល់បុគ្គលិក។ ពេលបុគ្គលិកមកដល់ សូមប្រគល់ក្រដាសគូសចម្លើយដែលអ្នកបានសរសេរចម្លើយ ក្រដាសសំណួរ និង"ឧទាហរណ៍នៃការសរសេរលើក្រដាសគូសចម្លើយនិងចំណុចប្រុងប្រយ័ត្នសម្រាប់ការប្រឡង" ទៅកាន់បុគ្គលិក ដើម្បីទទួលការពិនិត្យ។
  ក្រោយការពិនិត្យ នៅពេលបុគ្គលិកប្រាប់ថា "អ្នកអាចចាកចេញបាន" សូមអ្នកយកអីវ៉ាន់របស់ខ្លួន រួចចាកចេញពីបន្ទប់ប្រឡង។
- បើអ្នកបានចាកចេញពីបន្ទប់ក្នុងអំឡុងពេលប្រឡង អ្នកនឹងមិនអាចចូលក្នុងបន្ទប់ម្តងទៀតឡើយ។
  ម្យ៉ាងទៀត អ្នកដែលបានបញ្ចប់ការប្រឡងហើយបានចាកចេញពីបន្ទប់ សូមចាកចេញពីមណ្ឌលប្រឡងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន។
- នៅអំឡុងពេល10នាទីមុនការប្រឡងបញ្ចប់ អ្នកមិនអាចចាកចេញពីបន្ទប់បានទេ។ សូមរង់ចាំរហូតដល់ពេលដែលបុគ្គលិកបានប្រមូលក្រដាសគូសចម្លើយដែលមានសរសេរចម្លើយ ក្រដាសសំណួរ និង"ឧទាហរណ៍នៃការសរសេរលើក្រដាសគូសចម្លើយនិងចំណុចប្រុងប្រយ័ត្នសម្រាប់ការប្រឡង" រួចរាល់គ្រប់ទាំងអស់។
  អ្នកមិនអាចចាកចេញពីបន្ទប់បានទេ រហូតទាល់តែបុគ្គលិកប្រាប់ថា "អ្នកអាចចាកចេញបាន"។

(7) ទង្វើខុសវិន័យប្រឡង

- បើអ្នកប្រព្រឹត្តទង្វើដូចខាងក្រោម អ្នកនឹងទទួលកាតលឿងនិងត្រូវបានព្រមាន។ បើអ្នកបានទទួលកាតលឿងចំនួន2សន្លឹក អ្នកនឹងបាត់បង់សិទ្ធិប្រឡង ហើយត្រូវចាកចេញពីការប្រឡង និងមិនត្រូវបានផ្តល់ពិន្ទុនោះឡើយ។

**[កាតលឿង = ប្រយ័ត្ន]** (កាតលឿង2សន្លឹក នឹងត្រូវបាត់បង់សិទ្ធិហើយត្រូវចាកចេញពីការប្រឡង)

① ករណីអ្នកបើកក្រដាសសំណួរ ឬ សរសេរចម្លើយ នៅមុនពេលការប្រឡងចាប់ផ្តើម។
② ករណីអ្នកនិយាយដោយគ្មានការអនុញ្ញាតក្នុងអំឡុងពេលប្រឡង។
③ ករណីអ្នកប្រព្រឹត្តទង្វើដែលត្រូវបានសង្ស័យថាកំពុង "ប្រាប់ចម្លើយទៅអ្នកដទៃ" "បញ្ជូនសញ្ញា" "សុំឱ្យអ្នកដទៃប្រាប់ចម្លើយ" "មើលចម្លើយរបស់អ្នកដទៃ"ជាដើមក្នុងអំឡុងពេលប្រឡង។
④ ករណីមានសម្លេងរោទ៍ឬសម្លេងញ័រជាដើម ពីទូរសព្ទដៃ ទូរសព្ទទំនើប នាឡិកាជាដើមក្នុងអំឡុងពេលប្រឡង។
⑤ ករណីអ្នកចម្លងសំណួរឬចម្លើយទៅលើអ្វីមួយក្រៅពីក្រដាសសំណួរឬក្រដាសគូសចម្លើយ។
⑥ ករណីអ្នកបង្កការរំខានដល់អ្នកដទៃ ហើយមិនធ្វើតាមការព្រមានរបស់បុគ្គលិក។
⑦ ករណីអ្នកក្រោកឈរដោយគ្មានការអនុញ្ញាត មុនពេលបុគ្គលិកបង្គាប់ ហើយមិនធ្វើតាមការព្រមានរបស់បុគ្គលិក
⑧ ករណីអ្នកបន្តសរសេរចម្លើយ ទោះជាបុគ្គលិកបាននិយាយថា "សូមបញ្ឈប់ការសរសេរនៅលើក្រដាសគូសចម្លើយ"ហើយក៏ដោយ។
⑨ ករណីអ្នកមិនប្រគល់ក្រដាសគូសចម្លើយទៅឱ្យបុគ្គលិកដែលកំពុងប្រមូលក្រដាសគូសចម្លើយក្រោយពេលបញ្ចប់ការប្រឡង។
⑩ ករណីដឹងថាអ្នកកំពុងទំពាស្ករកៅស៊ូឬបៀមស្ករជាដើម ឬផឹកភេសជ្ជៈ ក្នុងអំឡុងពេលប្រឡង។
⑪ ទង្វើផ្សេងទៀតដែលបុគ្គលិកបានព្រមាន ហើយអ្នកមិនអនុវត្តតាម។

- បើអ្នកប្រព្រឹត្តទង្វើដូចខាងក្រោម អ្នកនឹងទទួលកាតក្រហម ដោយអ្នកនឹងបាត់បង់សិទ្ធិប្រឡង ហើយត្រូវចាកចេញពីការប្រឡង និងមិនត្រូវបានផ្តល់ពិន្ទុនោះឡើយ។

**[កាតក្រហម = បាត់បង់សិទ្ធិ/ចាកចេញពីការប្រឡង]** (កាតក្រហម1សន្លឹក នឹងត្រូវបាត់បង់សិទ្ធិហើយត្រូវចាកចេញពីការប្រឡង)

① ករណីបេក្ខជនប្រឡង និង មនុស្សនៅលើប័ណ្ណប្រឡងជាមនុស្សខុសគ្នា។
② ករណីអ្នកសរសេរចម្លើយនៅលើក្រដាសគូសចម្លើយរបស់អ្នកដទៃ ឬ សុំឱ្យគេសរសេរលើក្រដាសរបស់ខ្លួន ឬ បានផ្លាស់ប្តូរក្រដាសសំណួរឬក្រដាសគូសចម្លើយ។
③ ករណីអ្នកប្រព្រឹត្តទង្វើបន្លំដោយលួចមើលឯកសារឬសៀវភៅមេរៀន រួមទាំងការប្រើប្រាស់ទូរសព្ទដៃផងដែរ ក្នុងអំឡុងពេលប្រឡង។
④ ករណីអ្នកបានប្រើម៉ាស៊ីនគិតលេខដែលមិនអាចប្រើបាន។
⑤ ករណីអ្នកបានយកក្រដាសសំណួរឬក្រដាសគូសចម្លើយចេញពីបន្ទប់ប្រឡង។
⑥ ករណីអ្នកបានចាកចេញពីបន្ទប់ នៅមុនពេលបុគ្គលិកប្រាប់ថា"អ្នកអាចចាកចេញបាន" ។

⑦ ករណីអ្នកបានចម្លងសំណួរឬចម្លើយដាក់លើអ្វីមួយ ហើយយកចេញពីបន្ទប់ប្រឡង។

- ■ អ្នកដែលប្រឡងឬមានបំណងប្រឡងដោយប្រើមធ្យោបាយមិនត្រឹមត្រូវ រួមទាំងការដាក់ពាក្យស្នូន នឹងមិនអាចចូលរួមការប្រឡងបានទេ។ ម្យ៉ាងទៀត ទោះជាបានប្រឡងជាប់ ក៏នឹងត្រូវបានលុបចោលវិញ ហើយបុគ្គលនោះអាចនឹងមិនអាចចូលរួមការប្រឡងរយៈពេល 5 ឆ្នាំជាអតិបរមា។

- ■ ទោះជាបេក្ខជនប្រឡងត្រូវជួបបញ្ហាដោយសារការប្រព្រឹត្តទង្វើខុសវិន័យប្រឡង ក៏នោះមិនមែនជាទំនួលខុសត្រូវឬកាតព្វកិច្ចជាដើមរបស់ OTAFFឡើយ។ ថ្លៃប្រឡងក៏នឹងមិនត្រូវបានសងត្រឡប់ជូនវិញដែរ។

(8) ការប្រុងប្រយ័ត្នផ្សេងៗទៀត

① អ្នកមិនអាចថតរូប ថតវីដេអូ ឬថតសម្លេងជាដើមបានទេនៅមណ្ឌលប្រឡង។

② បើអ្នកជក់បារី សូមជក់នៅកន្លែងដែលបានកំណត់រួចស្រេច។

③ សូមអ្នកកុំចូលទៅក្នុងតំបន់ដែលត្រូវបានហាមឃាត់នៅមណ្ឌលប្រឡងឱ្យសោះ។

④ សូមកុំប៉ះពាល់បរិក្ខារជាដើមនៅមណ្ឌលប្រឡង។

⑤ នៅមណ្ឌលប្រឡង គឺគ្មានបន្ទប់សម្រាប់ទារកឬកុមារនោះទេ។

⑥ មានតែបេក្ខជនប្រឡងប៉ុណ្ណោះដែលអាចចូលទៅក្នុងមណ្ឌលប្រឡងបាន។ (អ្នកមិនអាចនាំមនុស្សផ្សេងទៀតចូលបានទេ)

⑦ នៅថ្ងៃប្រឡង អ្នកមិនអាចហៅទូរសព្ទឬផ្ញើសារតាមទូរសព្ទជាដើមទៅកាន់បេក្ខជនប្រឡងបានទេ។

## 10. ការប្រកាសបេក្ខជនប្រឡងជាប់ និង លិខិតបញ្ជាក់ការប្រឡងជាប់

(1) ការប្រកាសបេក្ខជនប្រឡងជាប់

អ្នកអាចមើលលទ្ធផលប្រឡងជាប់ឬធ្លាក់នៅលើគេហទំព័រនៃ OTAFF និងត្រង់"ប្រវត្តិនៃការប្រឡង"នៃទំព័រខ្ញុំ ក្នុងអំឡុងពេលប្រមាណ 3 សប្តាហ៍ ក្រោយបញ្ចប់កាលវិភាគនៃការប្រឡងទាំងអស់។ ទៅតាមនីតិវិធី ការប្រកាសលទ្ធផលប្រឡងគឺអាចយឺតយ៉ាវបន្ថែមទៀត។ សម្រាប់ព័ត៌មានលម្អិត សូមពិនិត្យមើល "កាលវិភាគប្រចាំឆ្នាំ" (https://otaff1.jp/schedule/schedule_jp.pdf)។ យើងខ្ញុំក៏ជូនដំណឹងអំពីការប្រកាសលទ្ធផលជាសាធារណៈតាមរយៈអ៊ីមែលដែលអ្នកបានចុះឈ្មោះផងដែរ។
យើងខ្ញុំមិនអាចឆ្លើយតបចំពោះការសាកសួរទាក់ទងនឹងលទ្ធផលប្រឡងបានទេ។

(2) ការទាញយកលិខិតបញ្ជាក់ការប្រឡងជាប់

លិខិតបញ្ជាក់ការប្រឡងជាប់សម្រាប់ការប្រឡងគិតចាប់ពីថ្ងៃទី1 ខែមេសា ឆ្នាំ2020 នឹងត្រូវបានបញ្ជូនចូលទៅក្នុងទំព័រខ្ញុំរបស់បេក្ខជនប្រឡងជាប់ នៅក្រោយការប្រកាសលទ្ធផលប្រឡង។
អ្នកអាចទាញយកចេញពី"ប្រវត្តិនៃការប្រឡង"នៅលើទំព័រខ្ញុំរបស់អ្នក ដូច្នេះ សូមបោះពុម្ពចេញដោយខ្លួនឯងនៅពេលចាំបាច់។
OTAFF មិនអាចទាញយកនិងបោះពុម្ពចេញបានទេ។

(3) រយៈពេលសុពលភាពនៃលិខិតបញ្ជាក់ការប្រឡងជាប់

រយៈពេលសុពលភាពនៃលិខិតបញ្ជាក់ការប្រឡងជាប់គឺ 10 ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតបញ្ជាក់ការប្រឡងជាប់។
លិខិតបញ្ជាក់ការប្រឡងជាប់នឹងចាំបាច់ត្រូវប្រើនៅក្នុងការស្នើសុំការប្រគល់លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ ឬ ការផ្លាស់ប្តូរលក្ខណៈសម្បត្តិស្នាក់នៅនៅប្រទេសជប៉ុន។

(ចំណុចប្រុងប្រយ័ត្ន)

■ ទាក់ទងនឹងលិខិតបញ្ជាក់ការប្រឡងជាប់របស់អ្នកដែលបានចូលរួមការប្រឡងក្នុងចន្លោះថ្ងៃទី1 ខែមេសា ឆ្នាំ2019 រហូតដល់ថ្ងៃទី31 ខែមីនា ឆ្នាំ2020 គឺរួមមានចំណុចដូចខាងក្រោម។

- លិខិតបញ្ជាក់ការប្រឡងជាប់របស់អ្នកដែលបានចូលរួមការប្រឡងក្នុងចន្លោះថ្ងៃទី1 ខែមេសា ឆ្នាំ2019 រហូតដល់ថ្ងៃទី31 ខែមីនា ឆ្នាំ2020 គឺនឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ទៅកាន់អាសយដ្ឋានក្នុងប្រទេសជប៉ុនដែលបេក្ខជនប្រឡងជាប់បានចុះឈ្មោះ។
  ប៉ុន្តែ ករណីអ្នកមិនបានទទួលលិខិតបញ្ជាក់ការប្រឡងជាប់នោះទេ ដោយសារអាសយដ្ឋានចុះឈ្មោះខុសឬដោយសារការផ្លាស់ទីលំនៅជាដើម លិខិតបញ្ជាក់អាចនឹងត្រូវបានបញ្ជូនត្រឡប់មកOTAFFវិញ ដូច្នេះ ករណីដូចនោះ សូមទាក់ទងទៅកាន់OTAFF។
- ប្រសិនបើអ្នកដែលបានចូលរួមប្រឡងនៅចន្លោះថ្ងៃទី1 ខែមេសា ឆ្នាំ2019 ដល់ ថ្ងៃទី31 ខែមីនា ឆ្នាំ2020 បានធ្វើបាត់លិខិតបញ្ជាក់ការប្រឡងជាប់ អ្នកអាចទទួលការផ្តល់លិខិតសារជាថ្មីបានតែ1ដងប៉ុណ្ណោះ។
  ប៉ុន្តែ យើងខ្ញុំអាចផ្តល់លិខិតសារជាថ្មីបានតែក្នុងអំឡុងពេលនៃលិខិតបញ្ជាក់ការប្រឡងជាប់មានសុពលភាពប៉ុណ្ណោះ។
- ករណីអ្នកចង់ស្នើសុំការផ្ញើឬការផ្តល់លិខិតបញ្ជាក់ការប្រឡងជាប់សារជាថ្មី សូមបេក្ខជនប្រឡងជាប់ជាសាមីខ្លួនទាក់ទងទៅកាន់OTAFFតាមរយ:អ៊ីមែលឬទូរសព្ទ។
- ការរៀបចំផ្ញើឬផ្តល់លិខិតបញ្ជាក់ការប្រឡងជាប់សារជាថ្មីនឹងត្រូវការរយ:ពេលប្រមាណ1ខែ។
- ការផ្ញើនឹងកំណត់យក"បង់ប្រាក់ពេលទៅដល់" ដូច្នេះ សូមអ្នកបង់ប្រាក់នៅពេលទទួលលិខិត។
- អាសយដ្ឋានសម្រាប់ផ្ញើឬផ្តល់លិខិតបញ្ជាក់ការប្រឡងជាប់សារជាថ្មីគឺបានត្រឹមតែនៅក្នុងប្រទេសជប៉ុនប៉ុណ្ណោះ។

【ទំនាក់ទំនង】

អាសយដ្ឋានអ៊ីមែល tokutei@otaff.or.jp

លេខទូរសព្ទ 03-6261-4949 (ថ្ងៃធ្វើការប៉ុណ្ណោះ ម៉ោង9:00~12:00 ឬ 13:00~17:00)

គេហទំព័រ https://otaff.or.jp/

(4) ការលុបចោលការប្រឡងជាប់

ករណីដឹងអំពីទង្វើខុសវិន័យប្រឡងក្នុងចំណោម①ដល់③ខាងក្រោម ក្រោយពេលប្រគល់លិខិតបញ្ជាក់ការប្រឡងជាប់ ការប្រឡងជាប់នោះនឹងត្រូវបានលុបចោល។

① ករណីអ្នកបានទាមទារការផ្តល់ព័ត៌មាននិងបានទទួលព័ត៌មានទាក់ទងនឹងការសម្ភាត់ដូចជាសំណួរប្រឡងជាដើមពីបុគ្គលពាក់ព័ន្ធនឹងការប្រឡង។

② ករណីអ្នកបានប្រព្រឹត្តទង្វើខុសវិន័យដោយចេតនាទាក់ទងនឹងខ្លឹមសារចុះឈ្មោះនៅលើទំព័រខ្ញុំ។

③ ករណីបានដឹងថាមានទង្វើខុសវិន័យប្រឡងផ្សេងទៀតក្រៅពីចំណុចខាងលើ។

ការលុបចោលការប្រឡងជាប់នឹងត្រូវបានរាយការណ៍ទៅកាន់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ស្របពេលនឹងជូនដំណឹងដល់បុគ្គលនោះអំពីការលុបចោលការប្រឡងជាប់ ទិន្នន័យទាក់ទងនឹងលិខិតបញ្ជាក់ការប្រឡងជាប់ដែលបានបញ្ជូនទៅក្នុងទំព័រខ្ញុំនឹងត្រូវបានលុបចោលផងដែរ។ (លិខិតបញ្ជាក់ការប្រឡងជាប់នៃអ្នកដែលបានប្រឡងក្នុងចន្លោះថ្ងៃទី1 ខែមេសា ឆ្នាំ2019 ដល់ថ្ងៃទី31 ខែមីនា ឆ្នាំ2020 គឺត្រូវបានផ្ញើតាមប្រៃសណីយ៍ ដូច្នេះ សូមបញ្ជូនត្រឡប់មកកាន់OTAFFវិញ។)

ម្យ៉ាងទៀត អ្នកអាចនឹងមិនអាចចូលរួមការប្រឡងរយៈពេល 5 ឆ្នាំជាអតិបរមា។

## 11. ការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន

ព័ត៌មានផ្ទាល់ខ្លួនដែលទទួលបានពីអ្នកទាំងអស់គ្នាសម្រាប់ការប្រឡងនេះ នឹងត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្ន ទៅតាមការចែងនៅក្នុងច្បាប់ស្តីពីការការពារព័ត៌មានផ្ទាល់ខ្លួន(ច្បាប់ឆ្នាំ2003 លេខ57)ជាដើម។

ព័ត៌មានផ្ទាល់ខ្លួនដែលបានចុះឈ្មោះនៅលើទំព័រខ្ញុំនឹងត្រូវបានប្រើប្រាស់សម្រាប់តែការប្រឡងរបស់OTAFFប៉ុណ្ណោះ។

គ្មានការផ្តល់ព័ត៌មានទាំងនេះទៅកាន់អ្នកដទៃឡើយ។

ករណីOTAFFត្រូវពឹងពាក់ការងារចំពោះភាគីទី3ដើម្បីអនុវត្តការប្រឡង នោះនឹងមានការផ្តល់ព័ត៌មានផ្ទាល់ខ្លួនក្នុងកម្រិតចាំបាច់សម្រាប់អនុវត្តការប្រឡង។ ក្នុងករណីនោះ OTAFFនឹងចុះកិច្ចសន្យាទាក់ទងនឹងការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនជាមួយនឹងស្ថាប័នដែលទទួលការងារ ហើយនឹងធ្វើការត្រួតពិនិត្យដោយសមស្រប។

យ៉ាងណាមិញ ករណីមានការស្នើសុំពីរដ្ឋាភិបាលដោយផ្អែកលើច្បាប់ប្បញ្ញត្តិជាដើម នោះអាចនឹងមានការផ្តល់ព័ត៌មានទៅដល់រដ្ឋាភិបាល។

ក្នុងចំណោមព័ត៌មានដែលបានចុះឈ្មោះនៅទំព័រខ្ញុំ ព័ត៌មានទាក់ទងនឹងឈ្មោះរាជធានីខេត្តក្រុងនិងខ្លឹមសារសម្រង់មតិជាដើម គឺអាចមានការប្រមូលទិន្នន័យនិងការប្រកាសលទ្ធផលនោះ ដោយមិនបង្ហាញអត្តសញ្ញាណបុគ្គល។